# មជ្ឈមណ្ឌលឯកសារកម្ពុជា

## របាយការណ៍ស្តីពី
## មន្ទីរសន្តិសុខនារបបខ្មែរក្រហមនៅក្នុងអតីតមន្ទីរពេទ្យវិកលចរិកព្រែកត្នោត
## ស្រុកតាខ្មៅ ខេត្តកណ្តាល

ដោយ ដេវីន ពន្សរ៉ាសុី

មន្ទីរពេទ្យជ័យជំនះបច្ចុប្បន្ន ជាឈ្មោះរបស់អតីតមន្ទីរពេទ្យវិកលចរិកព្រែកត្នោត ដែលប្រជាជនយើងបានដឹងនរេសព្វគ្រប់ៗគ្នាថា ជាមន្ទីរពេទ្យសម្រាប់ទទួលព្យាបាលជម្ងឺសរសៃប្រសាទកាលពីបីរជំនាន់មុនរបបខ្មែរក្រហម ។

តាំងពីឆ្នាំ១៩៥៥មក មន្ទីរពេទ្យនេះគ្រប់គ្រងដោយលោកវេជ្ជបណ្ឌិត សុន ម៉ន រហូតដល់ឆ្នាំ១៩៦៤ ។ មន្ទីរពេទ្យនេះត្រូវបានផ្លាស់ប្តូរឈ្មោះជាមន្ទីរពេទ្យ សុន ម៉ន ចាប់ពីឆ្នាំ១៩៦៤ មកទល់នឹងឆ្នាំ១៩៧៥ បន្ទាប់ពីមានការផ្លាស់ប្តូរអ្នកគ្រប់គ្រងថ្មីរួចមក ។ វេជ្ជបណ្ឌិត ចំរើន សំអឿនជាអ្នកគ្រប់គ្រងថ្មីមកជំនួសលោកវេជ្ជបណ្ឌិតចាស់ឈ្មោះ សុន ម៉ន ដែលបានទទួលមរណៈភាពនៅមន្ទីរពេទ្យកាល់ម៉ែត្រ ដោយជម្ងឺកាលពីឆ្នាំ១៩៦៤ ។ មន្ទីរពេទ្យនេះបានបំពេញការងាររបស់ខ្លួនរហូតដល់ថ្ងៃទី១៥ ខែមេសា ឆ្នាំ១៩៧៥ទើបបញ្ចប់ក្រោមការវាយបែកទីក្រុងតាខ្មៅ ។ ហើយបន្ទាប់ពីនោះមកត្រូវបានក្លាយជាកន្លែងឃុំឃាំងមនុស្សរហូតជិតដល់ថ្ងៃជ័យជំនះ ៧មករា ១៩៧៩ ។ ក្រោយព្រឹត្តិការណ៍នៃថ្ងៃជ័យជំនះរបស់ពួកខ្មែរក្រហមនៅខែមេសា ឆ្នាំ៧៥ មិនបានប៉ុន្មានថ្ងៃផង ស្រាប់តែមានការជម្លៀសប្រជាជន ព្រមទាំងដេញបុគ្គលិកនៃមន្ទីរពេទ្យឲ្យចេញទាំងអស់ ។

អន្តហេតុនេះគឺផ្អែកជាមូលដ្ឋានទៅលើកសិណផ្ទាល់មាត់ពីជនរងគ្រោះដែលជាអតីតបុគ្គលិកមន្ទីរពេទ្យវិកលចរិកតាំងពីឆ្នាំ១៩៥៥ ឈ្មោះដោក សុខខៃ ហើយក្រោយរបបប៉ុល ពត គាត់នៅមានជីវិតរស់នៅទៀតនោះ បានប្រាប់ថាគាត់បានឃើញមានស្នាមទំលុះជញ្ជាំង ដើម្បីស៊ករនុកដែក ដែលដោតភ្ជាប់នឹងខ្នោះដាក់កជើងជនរងគ្រោះ ។ ជនរងគ្រោះសុទ្ធតែជនពិការដែលប្រមូលមកពីទីក្រុងភ្នំពេញ ក៏ដូចជាពីកន្លែងផ្សេងៗទៀត ត្រូវបានពួកខ្មែរក្រហមយកទៅសម្លាប់ក្រោយពេលធ្វើទារុណកម្មនៅក្នុងបរិវេណមន្ទីរឃុំឃាំងនៃមន្ទីរពេទ្យវិកលចរិក ។ សាកសពដែលបានស្លាប់ហើយនោះត្រូវបានពួកខ្មែរក្រហមយកទៅកប់រួចដាំដើមដូងពីលើផ្នូរនោះក្នុងគំនិតធ្វើជាជីឲ្យដូងល្អ ។

ដើមដូងដែលបានដាំជាង១៣០ដើមកាលពីជំនាន់ ប៉ុល ពតនៅក្នុងបរិវេណមន្ទីរពេទ្យនេះ សុទ្ធតែត្រូវបានកប់សាកសពពីក្រោមទាំងអស់ ។បច្ចុប្បន្នដើមដូងទាំងនោះរីកលូតលាស់ស្ទើរស្មានមិនដល់ ។ នៅឆ្នាំ១៩៨០ យោងតាមសម្តីរបស់សាក្សីថា ឃើញមានខ្មោះជាច្រើនស្ថិតនៅរាយប៉ាយទាំងក្នុងបន្ទប់ និងក្រៅបន្ទប់នៃអគារ ជ ដែលបច្ចុប្បន្ន,ជាអគារពិនិត្យជម្ងឺទូទៅនៃមន្ទីរពេទ្យជ័យជំនះ ជាពិសេសមានរំពាត់ និងតុដែលទំនងជាតុសម្រាប់សួរចម្លើយ ។

រហូតមកដល់សព្វថ្ងៃ យើងសង្កេតឃើញនៅមានឥដ្ឋការ៉ូខុសប្លែកដដែល គ្រង់ថាឥដ្ឋការ៉ូចាស់ពណ៌ស តែត្រូវប៉ះភ្ជិតដោយឥដ្ឋការ៉ូពណ៌ក្រហម ឬលឿង ។ របារ(ចំរឹង) ដែលនៅតាមបង្អួចគ្រប់កន្លែងនៃអគារ ជ ដែលមានស្រាប់តាំងពីដើមមក ក៏មានការដាក់ថែមខ្លះៗទៀតនៅតាមកន្លែងផ្សេងៗដូចជា បន្ទប់រដ្ឋបាលជាដើម ។ ចំរឹងដែកដែលត្រូវបានបង្កើតថ្មីនេះ គឺកើតមានឡើងនៅក្នុងជំនាន់ខ្មែរក្រហមនៅកាន់អំណាច ។ ហើយចំរឹងដែលមានស្រាប់ពីសង្គមចាស់នោះគឺត្រូវបានធ្វើឡើងសម្រាប់ការពារមនុស្សវិកលចរិកមិនឲ្យដើរពាសវាលពាសកាល ។

អគារមួយនេះស្ថិតនៅតាមបណ្តោយថ្ងៃមានពីរជាន់ និងមានជាង៣០បន្ទប់ ។ ថ្វីត្បិតតែមានការជួសជុលខ្លះក៏ដោយ អគារមួយនេះហាក់មិនដូចជាអគារសម្រាប់ព្យាបាលអ្នកជម្ងឺសោះ គឺដូចទាំងស្រុងទៅនឹងមន្ទីរឃុំឃាំងសុទ្ធសាធ ។ ចំរឹងដែកបញ្ឈរយ៉ាងជគ្រឹងនៅច្រកទ្វារធំ មុនពេលចូលទៅកាន់បន្ទប់និមួយៗ ។ ស្លាកស្នាមទាំងឡាយដូចជាការទំលុះជញ្ជាំងសម្រាប់ស៊ករនុកដែក, ចោះប្រហោងសម្រាប់អ្នកទោសនោម...មិនត្រូវបានលុបបាត់ទាំងស្រុងទេ ។ នៅក្នុងបន្ទប់មួយៗនៃអគារពិនិត្យជម្ងឺទូទៅនេះ ពិតជាមានស្លាកស្នាមយ៉ាងច្បាស់ក្រឡែតបង្ហាញនូវភាពខុសគ្នាទាំងស្រុងរវាងឥតការ៉ូពណ៌ស លឿង និងក្រហម ។ ក្នុងចំណោមជាង៣០បន្ទប់(ទាំងជាន់ក្រោម និងជាន់ទី១) មាន២៨បន្ទប់ត្រូវបានពួកខ្មែរក្រហមយកធ្វើជាកន្លែងឃុំឃាំងអ្នកទោស ។ ចំណែកសល់ពីនោះជាបន្ទប់តូចៗ ដែលជាអតីតបន្ទប់ចែកថ្នាំ និង បង្គន់ ។

ខាងក្រោមនេះជាសម្តីរបស់ជនរងគ្រោះ ដែលបានដឹងរឿងរ៉ាវជាច្រើននៅក្នុងមន្ទីរពេទ្យនេះតាំងពីមុន និងក្រោយបែកទីក្រុងតាខ្មៅ ជាពិសេសនៅក្រោយថ្ងៃរំដោះ១៩៧៩ ។

កិច្ចសម្ភាសន៍ជាមួយលោក ដោក សុខខៃ មានដូចខាងក្រោមៈ

ខ្ញុំមានអាយុ ៦៥ ឆ្នាំ មានស្រុកកំណើតនៅឃុំតាខ្មៅ ស្រុកកណ្ដាលស្ទឹង ខេត្តកណ្ដាល ហើយបច្ចុប្បន្នរស់នៅភូមិព្រែកអញ្ចាញ ឃុំព្រែកឬស្សី ស្រុកតាខ្មៅ ខេត្តកណ្ដាល ។ ពីឆ្នាំ ១៩៥៥ដល់ខែមេសា ឆ្នាំ១៩៧៥ ខ្ញុំបានបម្រើការនៅមន្ទីរពេទ្យវិលចរិក ហើយនៅក្រោយថ្ងៃរំដោះ១៩៧៩ ខ្ញុំបានចូលមកកាន់មន្ទីរពេទ្យនេះនៅឆ្នាំ១៩៨០ ។ កិច្ចការរដ្ឋបាលជាកិច្ចការរបស់ខ្ញុំតាំងពីចូលបម្រើការដំបូងរហូតដល់ចូលនិវត្តន៍នៅឆ្នាំ១៩៩២ ។ កាលពីជំនាន់ខ្មែរក្រហមកាន់អំណាច(១៩៧៥ - ៧៩) ខ្ញុំពុំបានរស់នៅជាប់នឹងមន្ទីរពេទ្យនេះ ហើយក៏មិនបានរស់នៅក្នុងខេត្តកណ្ដាលដែរ គឺត្រូវបានជម្លៀសទៅនៅឯខេត្តពោធិសាត់ឯណោះ បន្ទាប់ពីមានការដេញយ៉ាងសង្កើញពីពួកខ្មែរក្រហមពីររូប(មិនស្គាល់ឈ្មោះ) នៅយប់ថ្ងៃទី៨ ខែឧសភា ឆ្នាំដដែល ក្រោយពេលដែលខ្ញុំបានបន្ទំខ្លួនរួមទាំងប្រពន្ធ និងកូនជាមួយហ្វូងមនុស្សវិកលចរិកដទៃទៀត ដើម្បីគេចខ្លួនមួយគ្រានោះ ។ រយៈពេល២០ថ្ងៃក្រោយវាយបែកទីក្រុងតាខ្មៅនាថ្ងៃទី១៥ខែមេសាឆ្នាំ១៩៧៥ ខ្ញុំត្រូវរស់នៅលាក់ខ្លួនរហូតជាមួយហ្វូងមនុស្សវិលកលចរិកដល់ថ្ងៃទី៥ខែឧសភាឆ្នាំ១៩៧៥ ។ ពួកខ្មែរក្រហមបានមកដេញបុគ្គលិកមន្ទីរពេទ្យចេញទាំងអស់ដោយប្រាប់ថា ប្រសិនបើនៅតទៅទៀតពិតជាត្រូវពួកអាមេរិកមកទម្លាក់គ្រាប់បែកស្លាប់អស់មិនខាន ។ គ្រួសាររបស់ខ្ញុំមានសមាជិកទាំងអស់១៣នាក់ ។ក្នុងហេតុការណ៍នេះ(១៥ មេសា ឆ្នាំ១៩៧៥ ដល់ថ្ងៃទី៥ ឧសភា ឆ្នាំ១៩៧៥) ខ្ញុំបានឃើញហេតុការណ៍កើតឡើងដូចជា មានការបាញ់ទម្លុះសោរទ្វារបញ្ចេញមនុស្សវិកលចរិកឲ្យដើរពាសវាលពាសកាលក្នុងបរិវេណពេទ្យ និងក្រៅមន្ទីរពេទ្យ បាញ់ទម្លាយឃ្លាំងគ្រប់គ្រងឱសថ ។ នៅថ្ងៃទី១៦ ខែមេសា ឆ្នាំ១៩៧៥ពួកខ្មែរក្រហមបានជញ្ជូនឥវ៉ាន់ដែលប្រមូលបាននោះយកទៅដាក់ឡានរួចដឹកយកទៅអស់ដោយមិនដឹងយកទៅទីណា ។ ក្នុងរយៈពេល២០ថ្ងៃនៃការស្នាក់នៅរបស់ខ្ញុំជាមួយពួកមនុស្សវិកលចរិកនានា ខ្ញុំត្រូវបានក្មេងខ្មែរក្រហមម្នាក់អាយុប្រមាណ ១២- ១៣ឆ្នាំ បាញ់ដោយកាំភ្លើងការ៉ាប៊ីនសំដៅទៅរកខ្ញុំនៅក្នុងបន្ទប់មួយនៃអគារជីក្លែវ៉ាំបុល ដែលបច្ចុប្បន្នជាអគាររបេង ។គ្រាប់ដែលហើរចេញពីកាណុងកាំភ្លើងនោះមិនបានហោះទៅត្រូវខ្ញុំឡើយ ។ បន្ទាប់មកក្មេងខ្មែរក្រហមនោះ បានដើរចេញទៅយ៉ាងព្រងើយក្រោយពីការបាញ់មួយគ្រាប់នេះមក ។ ខ្ញុំថែមទាំងបានឃើញពួកមនុស្សវិកលចរិកមួយចំនួនដែលដើរពាសវាលពាសកាលនោះ ទៅ

រើយកខោអាវទាហានដែលពួកទាហានលន់ ណុល បានដោះចោលនៅពីមុខទីធ្លា ក៏ដូចជានៅខាងក្រោមន្ទីរពេទ្យយកមកស្លៀក ប្រសិនបើមានកាំភ្លើងទៀតនោះ ពួកគេនឹងយកកាំភ្លើងនោះមកកាន់រួចធ្វើឫកក្អេងក្អាង ហាក់ដូចជាខ្លួនជានាយទាហានអញ្ចឹង ។ នៅពេលបន្ទាប់ ក៏មានខ្លះត្រូវបានពួកខ្មែរក្រហមសម្លាប់ភ្លាមៗ និងខ្លះទៀតបានកៀរឲ្យទៅកន្លែងឆ្ងាយៗពីមន្ទីរពេទ្យ ព្រោះពួកខ្មែរក្រហមយល់ថាជាទាហានរបស់ពួកលន់ ណុលពិតៗ ។ កាលនោះ(ពាក់កណ្តាលខែមេសា ឆ្នាំ ១៩៧៥) ខ្ញុំត្រូវបានពួកខ្មែរក្រហមឲ្យនៅចិញ្ចឹមជ្រូក ព្រមទាំងកាប់ជ្រូកនៅពេលដែលពួកគេត្រូវការរកស៊ី ។ ដោយសារតែមានឱកាសចេញក្រៅយ៉ាងនេះហើយ ទើបបានជាដឹងដូច្នេះ ។ ប្រហែលជាម៉ោង ៨យប់ ថ្ងៃទី៤ ខែឧសភា ឆ្នាំដដែល ខ្ញុំត្រូវបានពួកខ្មែរក្រហមពីរនាក់មកគោះទ្វារឲ្យបើកនៅអតីតអគារសម្រាប់ដាក់ព្រះសង្ឃវិកលចរិក ដែលជាអំណោយរបស់ព្រះមហាក្សត្រីយានីសម្រាប់សម្រាប់តែព្រះសង្ឃ ព្រមទាំងហៅឈ្មោះចំៗតែម្តងថា «ខែ ខែ ចេញមកក្រៅមានការបន្តិច» ។ ទ្វាររបើកឡើង ខ្ញុំបានឃើញមនុស្សពីរនាក់មានកាន់ពិលពីរដែរ ក្នុងនោះមានម្នាក់បានដកកាំភ្លើងខ្លីមកភ្ជុងចំដើងសក់របស់ខ្ញុំ ដោយចោទថាខ្ញុំជាប្រធានមន្ទីរពេទ្យ ។ ពេលនោះខ្ញុំបានប្រាប់ទៅវិញថា ខ្ញុំមិនមែនជាប្រធានមន្ទីរពេទ្យទេ គឺជាមនុស្សវិកលចរិកដូចគេដូចឯងដែរ តែនៅក្នុងលក្ខណៈច្បាប់របស់ពេទ្យ ខ្ញុំជាមុគ្គលិកពេទ្យនៅមន្ទីរពេទ្យស្រុកកំពង់ហ្លួងឯណោះ ប៉ុន្តែមានជម្ងឺទើបត្រូវបានបញ្ជូនមកកាន់មន្ទីរពេទ្យនេះ ដើម្បីជាទម្លាប់ធ្វើការក្នុងការលើកក្រដាស លើកនេះលើកនោះ ប៉ុន្តែឲ្យសរសេរជាផ្លូវការមិនបានទេ ព្រោះខ្ញុំជាមនុស្សឆ្កួតទៅហើយ ។ នេះជាសម្តីរបស់ខ្ញុំប្រាប់ទៅទាហានខ្មែរក្រហមពីរនាក់នោះ ។ ក្រោយពីបានស្តាប់ហេតុផលរួច ខ្មែរក្រហមពីររូបនោះបានដេញខ្ញុំចេញពីបរិវេណមន្ទីរពេទ្យ ដោយដាក់កម្រិតថា «ខែឯងត្រូវតែចេញនៅថ្ងៃស្អែកដាច់ខាត» ។

ក្នុងអំឡុងពីថ្ងៃទី១៥ ខែមេសា ឆ្នាំ១៩៧៥ ដល់ថ្ងៃទី៥ ខែឧសភា ឆ្នាំ១៩៧៥ ជីវិតរបស់ខ្ញុំព្រមទាំងគ្រួសារបានរស់ក្នុងសភាពភ័យខ្លាចណាស់ បន្ទាប់ពីមានការចាកចេញទៅកាន់ខេត្តពោធិសាត់ក្រោយ ពីការដេញរបស់ពួកខ្មែរក្រហមពីរនាក់នោះ ។ ក្រោយពេលចាកចេញពីមន្ទីរពេទ្យ ខ្ញុំបានធ្វើដំណើររហូតទាល់តែដល់ខេត្តពោធិសាត់នៅឆ្នាំ១៩៧៦ ។

ប៉ុន្តែនៅក្រោយឆ្នាំ១៩៨០ ខ្ញុំបានវិលមករស់នៅស្រុកកំណើតវិញជាមួយកូនប្រុសម្នាក់ និងកូនស្រីម្នាក់ ។ ខ្ញុំក៏បានចូលទៅកាន់មន្ទីរពេទ្យវិលចរិកវិញនៅពេលបន្ទាប់ ដើម្បីរៀបចំមន្ទីរពេទ្យឡើងវិញសម្រាប់បម្រើដល់ប្រជាជនដែលនៅសេសសល់ពីការស្លាប់ ។ ខ្ញុំបានឃើញមានស្លាក់ស្នាមប្រមាមដៃប្រឡាក់ឈាម ដែលមានស្នាមអូសពីលើមកក្រោមនៅជាប់នឹងជញ្ជាំងបន្ទប់នៃអគារមួយដែលស្ថិតនៅតាមបណ្តោយថ្ងៃ ដែលសព្វថ្ងៃជាអគារ ជ ឬអគារពិនិត្យជម្ងឺទូទៅ ។ ខ្នោះជើងជាច្រើនដែលស្ថិតនៅពាសពេញបន្ទប់ និងក្រោបន្ទប់នៃបរិវេណមន្ទីរពេទ្យ ត្រូវបានខ្ញុំរួមជាមួយបុគ្គលិកពេទ្យមួយចំនួនទៀតប្រមូលញយកទៅបោះចោលនៅប៉ែកខាងក្រោយនៃមន្ទីរពេទ្យ គឺយកទៅគរនៅក្នុងចម្ការចេក និងក្រោមដើមម៉ៃសាក់យ៉ាងច្រើន ។ ខ្នោះទាំងនោះមានរាងជាអក្សរអ៊ិយ[១៤] រូបមានពត់មូលក្រវង់នៅផ្នែកខាងក្បាលទាំងពីរ សម្រាប់ស៊ិករនុកដែកមួយដែលមានទំហំ២០លី និងមានចាក់សោរផង ។ បន្ទប់និមួយៗនៃអគារជ សុត្ធតែមានស្នាមចោះទម្លុះប្រហោងនៅសងខាងមាត់ទ្វារចូល ដើម្បីធ្វើជាកន្លែងស៊ិករនុកដែកដែលបានស៊ិកតាមខ្នោះដាក់ករជើងអ្នកទោសរួចចាក់សោរភ្ជាប់ជាមួយនឹងគន្លឹះដែលដែលស្ថិតនៅប៉ែកខាងក្រោបន្ទប់ ។ សព្វថ្ងៃប្រហោងទាំងនោះត្រូវបានបិតភ្ជិតដោយខ្ញុំនឹងបុគ្គលិកនៃមន្ទីរពេទ្យដទៃទៀតកាលពីឡុងទសវត្សរ៍ទី៨០ម្ល៉ោះ ។ ឥដ្ឋការ៉ូដែលបានប៉ះប្រហោងទាំងនោះមិនត្រូវបានបិទឡូដូចឥដ្ឋការ៉ូចាស់ឡើយ ព្រោះកាលនោះ(១៩៨០) ខ្ញុំបានដើររើសយកឥដ្ឋការ៉ូពីនេះបន្តិច ពីនោះបន្តិចក្នុងបរិវេណមន្ទីរពេទ្យវិលចរិកនេះមកប៉ះ ។

ដើម្បីឲ្យបានដឹងច្បាស់ជាងហ្នឹងទៅទៀត សូមតាមដានពីកិច្ចសម្ភាសន៍ជាមួយលោក សាយ ពេញ ដែលជាប្រធានផ្នែករដ្ឋបាលនៃមន្ទីរពេទ្យជ័យជំនះ ហើយក៏ជាមនុស្សដំបូងដែលបានចូលមកបម្រើការនៅក្នុងមន្ទីរពេទ្យនេះនៅក្រោយឆ្នាំ១៩៧៩ ។

អ៊ំប្រុស សាយ ពេញ អាយុ ៥៣ ឆ្នាំ

ខ្ញុំមាននាទីបច្ចុប្បន្នជាប្រធានផ្នែករដ្ឋបាលនៃមន្ទីរឡេជ័យជំនះ ។ ក្នុងរបបសីហនុ ខ្ញុំធ្វើការនៅក្នុងមន្ទីរពេទ្យអគ្គខ្ទង ។ លុះក្រោយឆ្នាំ១៩៧៩ ក្នុងខែមិថុនា ខ្ញុំបានចូលមកធ្វើការនៅក្នុងមន្ទីរពេទ្យជ័យជំនះបច្ចុប្បន្ននេះ តាមសំណើរសុំរបស់មន្ទីរខេត្តកណ្តាល ។ ពេលមកដល់ដំបូងខ្ញុំបានឃើញមន្ទីរពេទ្យនេះ មានសុទ្ធតែព្រៃក្រាស់ៗ សឹងតែមើលមិនឃើញពីអគារមួយទៅអគារមួយ

ទៀត ។ ខ្ញុំថ និងលោកនួវ ហ៊ិន(មិនបានបញ្ជាក់ពីមុខងារ ទីលំនៅ ឬ ស្លាប់ រស់ទេ) ដែលជាអ្នកចូលមកធ្វើការមុនគេនោះ បានទៅចូលរៀបចំតាមបន្ទប់មួយៗនៃគ្រប់អគារក្នុងមន្ទីរពេទ្យទាំងអស់ដើម្បីរៀបចំឲ្យអ្នកជម្ងឺស្នាក់នៅព្យាបាល ។ ក្នុងពេលរៀបចំបន្ទប់នៅក្នុងអគារជ ដែលពីសម័យមុនប៉ុល ពតជាអគារមើលជម្ងឺរបេង ហើយបច្ចុប្បន្នជាអគារមើលជម្ងឺទូទៅ មានសុទ្ធតែខ្នោះឃ្នៀងឡោសុី ព្រមទាំងមានគុ រំពាត់...។ តាមការសន្និដ្ឋានរបស់ខ្ញុំថាប្រហែលជាកន្លែងសួរចម្លើយ និងជាកន្លែងឃុំឃាំងអ្នកទោស ។ នៅតាមបន្ទប់មួយៗមានស្នាមចោះប្រហោងសម្រាប់ឲ្យអ្នកទោសនោម ។ នៅពេលដែលខ្ញុំចូលមកកាន់មន្ទីរពេទ្យនេះដំបូង ខ្ញុំបានឮអ្នកជម្ងឺដែលមានសភាពធន់ធ្ងរអស់កម្លាំង ដោយសារការបង្អត់អាហាររបស់ខ្មែរក្រហមនិយាយប្រាប់ថា មន្ទីរពេទ្យនេះជាគុកមួយសម្រាប់ដាក់តែអ្នកទោសជាជនពិការដែលប្រមូលមកពីទីក្រុង ឬពីកន្លែងនានាក្នុងប្រទេស ។ ជនពិការទាមងនោះត្រូវបានពួកខ្មែរក្រហមបញ្ជារឲ្យជីកអណ្តូងចំនួនបីក្នុងបរិវេណមន្ទីរពេទ្យប៉ែកខាងជើង ។ អណ្តូងទាំងបីដែលបានជីកនោះ នឹងត្រូវយកធ្វើជាកន្លែងកប់មនុស្សរបស់ពួកខ្មែរក្រហមនៅថ្ងៃទី២០ ខសភា ឆ្នាំ១៩៧៥ ដែលជាថ្ងៃសម្លាប់មនុស្សដំបូងរបស់ពួកខ្មែរក្រហមនៅទីនោះ ។ សព្វថ្ងៃមន្ទីរពេទ្យនេះ មានសុទ្ធតែដើមដូងជាជួរៗតាមបណ្តោយដងផ្លូវក្នុងមន្ទីរពេទ្យដែលពីជំនាន់សីហនុ លន់ ណុល មិនដែលមានសោះ ។ តាមរបាយការណ៍ដែលខ្ញុំបានធ្វើឡើងគឺមានចំនួនជាង ១៣០ដើម ។ ដើមដូងទាំងនេះត្រូវបានដាំនៅក្នុងជំនាន់ប៉ុល ពត ។ មុនពេលដាំដើមដូងនេះពួកខ្មែរក្រហមមានយកសាកសពមួយមកកប់សិនបន្ទាប់មកក៏យកដើមដូងមួយមកដាំពីលើសាកសពនោះ ។ មានសាកសពចំនួនប្រហែលជាង១៣០នាក់នៅពីក្រោមដើមដូងជាង១៣០ដើមនោះ ។ សាកសពដែលត្រូវយកមកកប់ គឺសុទ្ធសឹងជាសាកសពជនពិការទាំងអស់ ។ នៅជុំវិញបរិវេណខាងក្រៅមន្ទីរពេទ្យឃើញមានសុទ្ធតែជនពិការដែលភាគច្រើនជាកម្មាភិបាល និងជាអ្នកធ្លាប់មានគុណសម្បត្តិរបស់ពួកខ្មែរក្រហមមកស្នាក់នៅតាមបញ្ជាពីថ្នាក់លើរបស់ពួកគេព្រមមានរៀបការប្រពន្ធស្អាតៗ ដែលជាកូនរបស់អ្នកស្រុកឲ្យពួកជនពិការទាំងនោះទៀតផង ។ ជនពិការដែលត្រូវមកជាប់នៅមន្ទីរឃុំឃាំងនៅក្នុងមន្ទីរពេទ្យជ័យជំនះ គឺយកមកភាគច្រើនពីភ្នំពេញដែលសុទ្ធីតែជាអ្នកមានបុណ្យសក្តិគ្រាន់បើ ។ ចំណែកឯជនពិការដែលស្ថិតនៅជាប់នឹងបរិវេណមន្ទីរពេទ្យវិញ គឺមិនត្រូវបានយកបន្តមកដាក់នៅក្នុងមន្ទីរសន្តិសុខនេះទេ ព្រោះជាកម្មាភិបាលនិងជាអ្នកមានគុណសម្បត្តិរបស់ពួកខ្មែរក្រហម ។